ព្រឹត្តិបត្រព័ត៌មាន

# ការប្រែប្រួលអាកាសធាតុ

#១០

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ

កក្កដា-កញ្ញា
២០១៧

## គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

### ការបង្កើតយន្តការសម្របសម្រួលជាមួយដៃគូលើផ្នែកប្រែប្រួលអាកាសធាតុ

ដោយមានកិច្ចខិតខំបង្កើនវិសាលភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងវិស័យឯកជន ដែលកំពុងធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកាន់តែមានចំនួនកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ កត្តានេះបាននាំមកនូវធនធានចាំបាច់បន្ថែមទៀត ប៉ុន្តែក៏អាចបណ្តាលឱ្យមានសកម្មភាពច្រំដែល និងអាចបង្កឱ្យមានប្រសិទ្ធភាពទាប។

ដោយទទួលស្គាល់ភាពចាំបាច់ក្នុងការកែលម្អការងារសម្របសម្រួលបញ្ហាបការប្រែប្រួលអាកាសធាតុនិងធានាបាននូវអត្ថប្រយោជន៍ខ្ពស់នៃការបន្សីជាមួយអាទិភាពជាតិ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) បានបង្កើតកិច្ចពិភាក្សាគោលនយោបាយជាប្រចាំរវាងក្រសួងស្ថាប័នរដ្ឋជាមួយដៃគូពាក់ព័ន្ធ រួមមាន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងវិស័យឯកជន។

ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ (ក.ប.ប.អ.) តំណាងឱ្យក្រសួងស្ថាប័នរដ្ឋចំនួន ២០ស្ថាប័នរួមបញ្ចូលទាំងក្រសួងស្ថាប័នដែលកំពុងអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នឹងធ្វើការជួបប្រជុំយ៉ាងតិចប្រាំមួយខែម្តងក្នុងមួយឆ្នាំជាមួយដៃគូ

តទៅទំព័រទី២



*អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បើកកិច្ចប្រជុំទី១របស់ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុជាមួយដៃគូ ថ្ងៃទី២៧ ខែមិថុនាឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ*

## កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

### ប្រតិបត្តិការកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំត្រៀមCOP23

កិច្ចប្រជុំត្រៀមសន្និសីទបណ្តាភាគីលើកទី ២៣ (pre-COP23) ត្រូវបានរៀបចំឡើងចាប់ពីថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០១៧ នៅកោះ Denarau Island ទីក្រុងNadi ប្រទេសហ្វីជី គឺនៅបីសប្តាហ៍មុនពេលកិច្ចប្រជុំCOP23 ដើម្បីផ្លាស់ប្តូរទស្សនៈអំពីបញ្ហាគន្លឹះដែលត្រូវសម្រេចនៅក្នុងCOP23។ គណៈប្រតិភូកម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រជុំត្រៀមនេះដែរ។

កិច្ចប្រជុំត្រៀមCOP23 ត្រូវបានរៀបចំឡើងដោយមានប្រធានបទសំខាន់ចំនួន៥ គឺ៖

១) លទ្ធផលរំពឹងទុកសម្រាប់COP23;
២) ប្រតិបត្តិការកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ;
៣) ហិរញ្ញវត្ថុហិរញ្ញវត្ថុ
៤) ការលើកកម្ពស់មហិច្ឆតានៃការចូលរួម

តទៅទំព័រទី៣

## មាតិកាព័ត៌មាន

គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត
- ការបង្កើតយន្តការសម្របសម្រួលជាមួយដៃគូលើផ្នែកប្រែប្រួលអាកាសធាតុ .......... ១
- ការពង្រឹងការគ្រប់គ្រងធនធានទឹកដែលធន់នឹងអាកាសធាតុនៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង .............................. ២
- ពិធីប្រកាសជាផ្លូវការនូវសមាសភាគសម្រាប់កម្ពុជានៃកម្មវិធី UNDP-Sida ថ្នាក់តំបន់ស្តីពីការពង្រឹងអភិបាលកិច្ចហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុដើម្បីពង្រីកសមភាពសមភាពយេនឌ័រ ២០១៧-២០២២ .................. ៣

កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ
- ប្រតិបត្តិការកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំត្រៀមCOP23 ............ ១

ការចេញផ្សាយបន្ទាប់ .................................. ៤
ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ ........... ៤
ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ ............. ៤

## ចំណាប់អារម្មណ៍របស់និពន្ធនាយក

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ។ ព្រឹត្តិបត្រព័ត៌មាននេះចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២និងទី៤នៃឆ្នាំនីមួយៗ យើងនឹងបន្ថែមការចែករំលែកបទពិសោធន៍សំខាន់ៗដែលអនុវត្តដោយអង្គការដៃគូនិងសហគមន៍នានាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ យើងខ្ញុំសង្ឃឹមថាប្រិយមិត្តអ្នកអាននឹងផ្តល់ធាតុចូលដូចជាការផ្តល់មេរៀនល្អៗនិងករណីសិក្សានានាដែលនាំឱ្យព្រឹត្តិបត្រនេះជោគជ័យ៕*

## ក្រុមការងាររៀបចំ និងត្រួតពិនិត្យ

*ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំកែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕*

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ការបង្កើតយន្តការសម្របសម្រួលជាមួយដៃគូ ...

*តពីទំព័រទី១*

នានាដែលកំពុងធ្វើការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

នៅក្នុងកិច្ចប្រជុំទីមួយដែលបានរៀបចំឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ដៃគូពាក់ព័ន្ធទាំងអស់បានធ្វើការពិភាក្សាអំពីលក្ខខណ្ឌការងារសម្រាប់ក្រុមការងារបច្ចេកទេសនិងដៃគូ។ កិច្ចពិភាក្សានេះក៏មានគោលបំណងបង្កើតការស្វែងយល់រួម ស្តីពី៖

- អាទិភាពរបស់កម្ពុជាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងបញ្ជាប់ជាមួយដំណើរការអន្តរជាតិ (ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ(CCAP) ការចូលរួមចំណែករបស់កម្ពុជា(INDC) ដំណើរការផែនការជាតិបន្សាំ(NAP)
- ក្របខណ្ឌស្ថាប័ន ផែនការ និងគ្រប់គ្រង សម្រាប់គម្រោងប្រែប្រួលអាកាសធាតុ
- តួនាទីរបស់ដៃគូអភិវឌ្ឍន៍ វិស័យអប់រំ និងវិស័យឯកជន ក្នុងការគ្រប់គ្រងព័ត៌មានប្រែប្រួលអាកាសធាតុ
- វិធីសាស្ត្រគ្រប់គ្រងគម្រោងឥណទានកាបូន និងការចូលរួមរបស់កម្ពុជាជាមួយមូលនិធិអាកាសធាតុបៃតង ដោយរួមបញ្ចូលទាំងកម្មវិធីត្រៀម និងការអភិវឌ្ឍសំណើគម្រោង។

កិច្ចប្រជុំទី២ នឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីពិភាក្សាពីចំណុចផ្តោតសំខាន់ៗនៃកម្មវិធីទាំងមូលប្រទេស រវាងកម្ពុជានិងមូលនិធិអាកាសធាតុបៃតង(GCF) សម្រាប់រយៈពេល៣ ទៅ ៥ឆ្នាំខាងមុខ។ កិច្ចពិភាក្សានឹងធ្វើការកំណត់សកម្មភាពបន្សាំ និងកាត់បន្ថយសមស្របបំផុតសម្រាប់ GCF និងសកម្មភាពមួយចំនួនដែលផ្តល់ឱកាសកាន់តែប្រសើរក្នុងការទទួលបានមូលនិធិតាមរយៈប្រភពផ្សេងទៀត៕




*លោកស្រី Kristina Kuhnel តំណាងស្ថានទូតស៊ុយអែដ/Sida បង្ហាញចំណាប់អារម្មណ៍ក្នុងការបង្កើតយន្តការសម្របសម្រួល ថ្ងៃទី២៧ ខែមិថុនាឆ្នាំ២០១៧ រាជធានីភ្នំពេញ*

## ការពង្រឹងការគ្រប់គ្រងធនធានទឹកដែលធន់នឹងអាកាសធាតុនៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងធនធានទឹកនិងឧតុនិយម កំពុងធ្វើការពង្រឹងភាពធន់នឹងអាកាសធាតុ និងកាត់បន្ថយហានិភ័យបណ្តាលមកពីទឹកជំនន់តាមរយៈការស្តារប្រព័ន្ធធារាសាស្ត្រនិងប្រព័ន្ធបង្ហូរទឹកដំណាក់ឈើក្រមុ។ ប្រព័ន្ធប្រឡាយនេះមានទីតាំងស្ថិតនៅជើងជួរភ្នំក្រវាញក្នុងខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង។ តំបន់នេះងាយរងគ្រោះខ្លាំងទៅនឹងជំនន់គំហុកពីភ្នំហើយធ្លាប់ជួបប្រទះភាពរាំងស្ងួតអូសបន្លាយកាលពីជាង១០ឆ្នាំមុន ដែលធ្វើឱ្យខូចខាតប្រព័ន្ធធារាសាស្ត្រនិងប្រព័ន្ធបង្ហូរទឹកនេះយ៉ាងខ្លាំង។

មុនពេលចាប់ផ្តើមសាងសង់ មន្ត្រីជំនាញបច្ចេកទេសនៃគម្រោងពង្រឹងការគ្រប់គ្រងទឹកជំនន់និងភាពរាំងស្ងួត ខេត្តពោធិ៍សាត់ បានធ្វើការជាមួយក្រសួងធនធានទឹកនិងឧតុនិយម ដើម្បីរៀបចំម៉ូដែលផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុទៅលើធនធានទឹករបស់ប្រឡាយនេះ។ ព័ត៌មាននេះនឹងជួយដល់ក្រុមវិស្វករអាចរៀបចំរចនាការងារស្តារដំណាក់កាលដំបូងសម្រាប់កាត់បន្ថយហានិភ័យគ្រោះរាំងស្ងួតនិងទឹកជំនន់នៅខេត្តពោធិ៍សាត់ ដោយប្រើប្រាស់ចំហាកប្រែប្រួលអាកាសធាតុស្រាលនាពេលអនាគត។ គម្រោងនេះទទួលការគាំទ្រពីមូលនិធិវិនិយោគអាកាសធាតុ ក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ធន់នឹងអាកាសធាតុកម្ពុជា (SPCR) តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី។

ស្របគ្នាដែរ គម្រោងនេះកំពុងបណ្តុះបណ្តាលប្រជាជនចំនួន៤៦ភូមិដែលរស់នៅជុំវិញប្រឡាយដំណាក់ឈើក្រមុ ដើម្បីបង្កើតនិងអនុវត្តផែនការភូមិមានសុវត្ថិភាពជាងមុន។ ផែនការភូមិមានសុវត្ថិភាពជាងមុន មានបញ្ជាក់ពីជំហានដែលសហគមន៍ត្រូវធ្វើ ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយរួមបញ្ចូលទាំងប្រព័ន្ធប្រកាសអាសន្នតាមដាននីវ៉ូទឹក ហើយជូនដំណឹងដល់អ្នកភូមិនៅពេលដែលត្រូវជម្លៀស។



*មន្ត្រីជំនាញបច្ចេកទេសរួមជាមួយមន្ត្រីជំនាញតាមវិស័យសិក្សាលទ្ធភាពនៃការពង្រីកប្រព័ន្ធប្រឡាយ នៅឆ្នាំ២០១៧ ក្នុងខេត្តពោធិ៍សាត់*

កម្មវិធីជំនួយបច្ចេកទេសរបស់SPCR សម្រាប់បញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍MCRDP កំពុងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួងធនធានទឹកនិងឧតុនិយម ក្នុងការកែលម្អប្រព័ន្ធធារាសាស្ត្រនិងប្រព័ន្ធបង្ហូរទឹកដំណាក់ឈើក្រមុ។ កម្មវិធីMCRDP ពិនិត្យមើលលទ្ធភាពនៃការពង្រីកសំណង់ប្រឡាយទឹកនិងប្រព័ន្ធធារាសាស្ត្រតាមរយៈការស្តារនិងតភ្ជាប់ដៃប្រឡាយនៅខេត្តបាត់ដំបងនិងខេត្តពោធិ៍សាត់។

កម្មវិធីMCRDP ក៏កំពុងស្វែងរកវិធានការសម្រាប់ផ្លូវជនបទដែលធន់នឹងអាកាសធាតុ កែលម្អផលិតកម្មកសិកម្មនិងទីផ្សារ និងកសាងភាពធន់របស់សហគមន៍ទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅពេលការសិក្សាបានបញ្ចប់ កម្មវិធីMCRDP នឹងជួយក្រសួងធនធានទឹកនិងឧតុនិយមស្វែងរកមូលនិធិបន្សាំសម្របសម្រួលដើម្បីកែលម្អការគ្រប់គ្រងធនធានទឹកដែលធន់នឹងអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់សហគមន៍ជុំវិញប្រឡាយដំណាក់ឈើក្រមុ៕

## ពិធីប្រកាសជាផ្លូវការនូវសមាសភាគសម្រាប់កម្ពុជានៃកម្មវិធីUNDP-Sida ថ្នាក់តំបន់ស្តីពីការពង្រឹងអភិបាលកិច្ចហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុដើម្បីពង្រីកសមភាពសមភាពយេនឌ័រ ២០១៧-២០២២

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(ក.ជ.អ.ច.) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត(Sida) បានប្រកាសជាផ្លូវការនូវ "សមាសភាគសម្រាប់កម្ពុជានៃកម្មវិធីUNDP-Sida ថ្នាក់តំបន់ស្តីពីការពង្រឹងអភិបាលកិច្ចហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ ដើម្បីពង្រីកសមភាពយេនឌ័រ ២០១៧-២០២២" នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧។ កម្មវិធីនេះគាំទ្រថវិកាដោយSida ដោយផ្តោតលើការពង្រឹងការធ្វើសមាហរណកម្មបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងថវិកាជាតិ ដោយគិតបញ្ចូលយេនឌ័រ និងក្រុមងាយរងគ្រោះ។ កម្មវិធីនេះនឹងបង្កើតភស្តុតាងកាន់តែច្បាស់នូវទំនាក់ទំនងរវាងការវិនិយោគដោយពិចារណាការប្រែប្រួលអាកាសធាតុ និងកំណើនសេដ្ឋកិច្ចនៅកម្រិតម៉ាក្រូ ហើយថាតើការវិនិយោគទាំងនេះមានឥទ្ធិពលយ៉ាងណាទៅលើក្រុមងាយរងគ្រោះ ដោយរួមបញ្ចូលទិដ្ឋភាពយេនឌ័រ។ លទ្ធផលទាំងនេះ នឹងក្លាយជាភស្តុតាងចាំបាច់សម្រាប់អ្នករៀបចំគោលនយោបាយក្នុងការរៀបចំផែនការបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្នុងការជួយឱ្យមានកំណើនសេដ្ឋកិច្ចនិងអត្ថប្រយោជន៍សង្គម។

នៅក្រោមកម្មវិធីថ្នាក់តំបន់ក្នុងរយៈពេលបីឆ្នាំមុន អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការធ្វើផែនការ និងប្រព័ន្ធថវិការដ្ឋ ដោយផ្តោតសំខាន់លើគោលដៅសំខាន់ចំនួនបី៖

១) ពង្រឹងសមត្ថភាពមន្ត្រីនៅកម្រិតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតាមដានការវិភាជន៍ហិរញ្ញប្បទានអាកាសធាតុ ស្វែងយល់អំពីចំណាយថ្លៃដើមនិងផលចំណេញ និងបង្ហាញនូវគោលការណ៍ណែនាំច្បាស់លាស់ដល់ក្រសួងតាមវិស័យនានាលើដំណើរការរៀបចំថវិកាជាតិ។ ជាលទ្ធផលពីឆ្នាំកន្លងទៅ ការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងសារាចរណែនាំស្តីពីការរៀបចំផែនយុទ្ធសាស្ត្រថវិកា និងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសិក្សា និងបោះពុម្ពផ្សាយប្រចាំឆ្នាំនូវរបាយការណ៍ស្តីពីការត្រួតពិនិត្យលើការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ(Climate Public Expenditure Review: CPER)។




*តំណាងUNDPទីក្រុងបាងកក អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ស្ថានទូតស៊ុយអែត និងUNDPប្រចាំកម្ពុជា ជាអធិបតីក្នុងសិក្ខាសាលាប្រកាសបើកកម្មវិធី ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ រាជធានីភ្នំពេញ*



*រូបថតជាក្រុមនៃសិក្ខាកាមដែលបានចូលរួមក្នុងពិធីបើក ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ រាជធានីភ្នំពេញ*

២) ផ្តោតសំខាន់លើការគាំទ្រក្រសួងវិស័យអាទិភាពមួយចំនួន ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីវិភាគលើសំណើសុំថវិការបស់ក្រសួងទាំងនេះ ដើម្បីកំណត់ភាពចាំបាច់ក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងជួយគាំទ្រដល់មន្ត្រីរៀបចំផែនការនៃក្រសួងទាំងនោះ ដើម្បី

*តទៅទំព័រទី៤*

## កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

### ប្រតិបត្តិការកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពី ...

*តពីទំព័រទី១*

ចំណែករបស់ជាតិ (NDCs)

៥) ការគ្រប់គ្រងហានិភ័យ និងភាពធន់នឹងអាកាសធាតុ។

កិច្ចប្រជុំនេះមានការចូលរួមពីនាយករដ្ឋមន្ត្រី ប្រធានគណៈប្រតិភូប្រែប្រួលអាកាសធាតុនិងប្រធានអ្នកចរចា ពីបណ្តាប្រទេសចំនួន៦៨ សរុបជាង៣០០នាក់។ នេះគឺជាកិច្ចប្រជុំត្រៀមCOP ធំបំផុតក្នុងប្រវត្តិសាស្ត្ររបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) ដែលបង្ហាញថាភាគីនានានៅតែប្តេជ្ញាចិត្តយ៉ាងសកម្មក្នុងការពន្លឿនដំណើរការកិច្ចព្រមព្រៀងទីក្រុងប៉ារីសនិងរៀបចំព័ត៌មានលម្អិតទាក់ទងនឹងបញ្ហាហិរញ្ញវត្ថុ សមត្ថភាព និងបន្ទេរបច្ចេកវិទ្យា។




*គណៈប្រតិភូចូលរួមកិច្ចប្រជុំត្រៀមសន្និសីទបណ្តាភាគីលើកទី២៣ ខែតុលា ឆ្នាំ២០១៧ ប្រទេសហ្វីជី*

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមាសភាគសម្រាប់ ...

តពីទំព័រទី៣

ភាគការចំណាយថ្លៃដើម និងផលចំណេញលើគម្រោងអាទិភាពទាំងឡាយដែលបញ្ជ្រាបការប្រែប្រួលអាកាសធាតុ។ ការវិភាគនេះបានផ្តល់នូវភស្តុតាងដើម្បីគាំទ្រដល់គម្រោងសំខាន់ៗ ដែលបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅពេលចចារថវិកាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣)ផ្តោតសំខាន់លើការអភិវឌ្ឍសមត្ថភាព និងការបង្កើតវគ្គបណ្តុះបណ្តាលក្នុងប្រទេសស្តីពីហិរញ្ញប្បទានអាកាសធាតុ។ យើងបានធ្វើការក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវសហប្រជាជាតិ(UNITAR) និងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៅកម្ពុជា ទាំងវគ្គ Online និងវគ្គផ្ទាល់។

គុណតម្លៃបន្ថែមនៃកម្មវិធីថ្នាក់តំបន់បាននាំមកនូវអ្នកជំនាញមានបទពិសោធន៍ល្អៗពីបណ្តាប្រទេសនានា ស្របពេលដែលយើងចង់បានជំនាញការដែលមិនចាំបាច់បំពេញការងារពេញម៉ោងនៅកម្ពុជា តួយ៉ាងវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់ត្រួតពិនិត្យការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ ឬសន្ទស្សន៍នៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងថវិកា ជាដើម៕

# ការចេញផ្សាយបន្ទាប់...



## សន្ទស្សន៍ភាពងាយរងគ្រោះនៃជីវភាពរស់នៅរបស់សហគមន៍ចំនួនបួននៅតំបន់រាមសារ ខេត្តស្ទឹងត្រែង

ខេត្តស្ទឹងត្រែងគឺជាខេត្តដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា និងធ្លាប់ជួបប្រទះគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ។ ហេតុនេះ ការសិក្សាវាយតម្លៃអំពីភាពងាយរងគ្រោះនៃជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់រាមសារត្រូវបានរៀបចំឡើង ដើម្បីកំណត់អនុសាសន៍ដោះស្រាយកត្តាបង្កឱ្យមានភាពងាយរងគ្រោះ។ យោងតាមក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះនៃជីវភាព មានកត្តាចំនួនបី គឺ ភាពប្រឈម ភាពរួស និងសមត្ថភាពបន្សាំ ត្រូវបានយកមកសិក្សាទៅកាន់គ្រួសារចំណាកចំនួន៣៥០គ្រួសារ នៅក្នុងឃុំចំនួន៤។ នៅក្នុងការចេញផ្សាយលេខបន្ទាប់ លោកអ្នកនឹងបានស្វែងយល់ពីសមាសភាគចម្បងនៃភាពងាយរងគ្រោះការប្រែប្រួលអាកាសធាតុ និងរបៀបដែលត្រូវដោះស្រាយ៕

# ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ



## ក្របខណ្ឌជាតិពិនិត្យតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ

នាយកដ្ឋានប្រែប្រួលអាកាសធាតុដោយមានការគាំទ្រពីវិទ្យាស្ថានអន្តរជាតិសម្រាប់បរិស្ថាននិងអភិវឌ្ឍន៍(IIED) និងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA) បានរៀបចំក្របខណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ(M&E) ដើម្បីតាមដានវឌ្ឍនភាពរបស់ប្រទេសក្នុងការដោះស្រាយបញ្ហាដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌជាតិM&E រួមបញ្ចូលទាំងសំណុំស្នូលនៃសូចនាករការត្រៀមស្ថាប័ន និងសូចនាករប៉ះពាល់។អភិក្រមចរន្តពីរទន្ទឹមគ្នា(Twin-track approach)ត្រូវបានប្រើប្រាស់នៅកម្រិតម៉ាក្រូ និងថ្នាក់ជាតិ ដើម្បីវាយតម្លៃថាតើកិច្ចប្រឹងប្រែងបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ នាំឱ្យមានការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងរបៀបអន្តរាគមន៍ដែលអាចជួយបង្កើនសមត្ថភាពរបស់សហគមន៍អាចបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌនេះបានដាក់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីពិនិត្យនិងអនុម័តចុងក្រោយ៕

# ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

- តុលា៖ កិច្ចប្រជុំលើកទី២ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- តុលា៖ ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវក្របខណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- វិច្ឆិកា៖ កិច្ចប្រជុំលើកទី២ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុជាមួយដៃគូ
- វិច្ឆិកា៖ ពិធីចុះអនុស្សរណៈលើភាពជាដៃគូរវាងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. និងសាកលវិទ្យាល័យស្តីពីការអភិវឌ្ឍដោយចីរភាព
- វិច្ឆិកា៖ សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុទៅកាន់និស្សិត និងយុវជន
- ធ្នូ៖ សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពីការស្រាវជ្រាវនិងការអនុវត្តនៅកម្ពុជា
- ធ្នូ៖ សិក្ខាសាលាចាប់ផ្តើមគម្រោងរៀបចំរបាយការណ៍ជាតិលើកទី៣(TNC) និងគម្រោងរៀបចំរបាយការណ៍បច្ចុប្បន្នកម្មពីរឆ្នាំម្តងដំណាក់កាលដំបូង(BUR)៕

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*

គាំទ្រដោយ
កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Supported by:
Ministry of Environment European Union UNDP Empowered lives. Resilient nations. SWEDEN

**ទំនាក់ទំនង**
នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +៨៥៥ ២៣ ៦៤០ ៣៨៣៣ | សារអេឡិចត្រូនិច៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh